## ***ដំណឹងលក់ដោយការដេញថ្លៃ***

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញនឹង ធ្វើការលក់ដេញថ្លៃឡាយឡុងនូវរថយន្តប្រើប្រាស់រួច ចំនួន ១ គ្រឿង ដល់សាធារណៈជនទូទៅ ។

## ***ទីតាំងលក់រថយន្តដេញថ្លៃ:***

ស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញ អគារលេខ ១ ផ្លូវលេខ ៩៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ។ ដោយអនុលោមតាមគោលការណ៍រក្សាគម្លាតសង្គមដើម្បីការពារជំងឺកូវីដ១៩  រថយន្តដែលត្រូវដេញថ្លៃនេះ នឹងពុំត្រូវបានដាក់អោយពិនិត្យមើលដោយផ្ទាល់នោះទេ ក៏ប៉ុន្តែអ្នកដេញថ្លៃដែលមានចំណាប់អារម្មណ៍នៅតែអាចមើលតាមរយៈរូបភាពដែលមានភ្ជាប់មកជាមួយនេះ ហើយបើមានសំនួរឬចម្ងល់ផ្សេងៗ សូមទំនាក់ទំនងតាមរយៈលេខទូរស័ព្ទដែលមានដាក់បង្ហាញខាងក្រោមនៃសេចក្តីជូនដំណឹងនេះ។

## ***កាលបរិច្ឆេទ និង ថេរពេលវេលានៃការដេញថ្លៃ:***

**ថ្ងៃព្រហស្បត៍ទី ២៣ ខែ កក្កដា ឆ្នាំ ២០២០ ដល់ថ្ងៃ ព្រហស្បត៍ ទី៣០ ខែកក្កដា ឆ្នាំ ២០២០**

**ម៉ោង ៨:00  ព្រឹក - ដល់ ម៉ោង ៥ ល្ងាច**

នៅក្នុងអំឡុងពេលដេញថ្លៃតាមកាលបរិច្ឆេទខាងលើ អ្នកដេញថ្លៃដែលមានចំណាប់អារម្មណ៍ ត្រូវផ្ញើរសន្លឹកដេញថ្លៃ របស់ខ្លួន ដោយមានបញ្ជាក់ច្បាស់អំពីចំនួនទឹកប្រាក់ដេញថ្លៃ (មិនទាន់គិតប្រាក់ពន្ធ) ឈ្មោះអ្នកដេញថ្លៃ លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង និងភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណចម្លង ឬលិខិតឆ្លងដែនមកជាមួយផង។

សូមផ្ញើរសន្លឹកដេញថ្លៃនៅក្នុងស្រោមសំបុត្របិទជិតមកកាន់អស័យដ្ឋានដូចខាងក្រោម៖

ស្ថានទូតអាមេរិក

អគារលេខ១ ផ្លូវលេខ ៩៦

សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ក្រុងភ្នំពេញ

Attn: លោកសំ សុភី

## ***លក្ខខណ្ឌនៃការលក់:***

- រថយន្តនឹងត្រូវលក់ជូនដល់អ្នកដេញថ្លៃដែលឲ្យតំលៃខ្ពស់បំផុត។
- រថយន្តដែលបានលក់ដូចឃើញនៅនឹងកន្លែងស្រាប់ ពុំអាចប្តូរជាប្រាក់វិញ និង គ្មានការធានាឡើយ។
- **ស្ថានទូតសហរដ្ឋអាមេរិក** រក្សាសិទ្ធិក្នុងការច្រានចោលនូវការដេញថ្លៃណាមួយដែលខ្លួនយល់ឃើញថាមិនសមនឹងតំលៃនៃរថយន្ត ឬក៏មានភស្តុតាងបញ្ជាក់ថា មានការសមគំនិតគ្នា ការឃុបឃិត ឬការទទួលសំណូកណាមួយ។
- ការបង់ប្រាក់: អ្នកដេញថ្លៃបាន ត្រូវបង់ប្រាក់គ្រប់ចំនួនជាសាច់ប្រាក់សុទ្ធភ្លាមៗដែលគេមិនអាចទារយកមកវិញបាន ក្នុងអំឡុងពេល៧២ម៉ោងដែលត្រូវបានទាក់ទង ទៅបេឡារបស់ស្ថានទូត ឬលេខគណនេយ្យរបស់ស្ថានទូត។ ពត៌មានលំអិតអពីរបៀបបង់ប្រាក់ នឹងត្រូវបានប្រាប់ទៅកាន់តែអ្នកឈ្នះការដេញថ្លៃតែប៉ុណ្ណោះ។ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ឬក្រសួងមន្ទីរនានា អាចធ្វើការសាកសួរទៅកាន់មន្ត្រីគយកម្ពុជាអំពីនិតិវិធីលើកលែងពន្ធ។
- រាល់ការរៀបចំ និងចំណាយនៅក្នុងការយកចេញនូវរថយន្តដែលដេញថ្លៃបាន គឺជាបន្ទុករបស់អ្នកទិញ។

- ការគណនាពន្ធ ត្រូវបានកំនត់ដោយស្ថាប័នមានសមត្ថកិច្ចរដ្ឋាករគយកម្ពុជា។ រថយន្តនេះ Toyota Land Cruiser ឆ្នាំ ១៩៩៨ ស្លាកលេខ CD25-166, លេខដៃ ទំហំស៊ីឡាំង ៤៥០០សេសេ ពណ៌ស ប្រើសាំង។ មានអត្រាគិតពន្ធ 152,45% នៃតម្លៃដែលតម្លៃដែលដេញថ្លៃឈ្នះ។
- នៅក្នុងករណីដែលអ្នកទិញខកខានមិនបានយករថយន្តដែលទិញបាននោះចេញពីទីតាំងលក់ ត្រឹមម៉ោង ៥ ល្ងាច ថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០២០, តាមការសំរេចរបស់ខ្លួន ស្ថានទូតអាមេរិកនៅភ្នំពេញ អាចទារថ្លៃថែររក្សាទុករថយន្តដែលអាចកើនឡើងរហូតដល់តំលៃនៃការដេញថ្លៃ ដែលបន្ទាប់ពីនោះ អ្នកដេញថ្លៃបានបាត់បង់សិទ្ធិក្នុងការយករថយន្តដែលទិញបាននោះ ហើយនិងប្រាក់ទាំងអស់ដែលបានបង់។
- ដើម្បីយករថយន្តចេញពីទីតាំងលក់បាន គេត្រូវបង្ហាញបង្កាន់ដៃបង់ប្រាក់មានចុះហត្ថលេខា ដែលចេញដោយបេឡារបស់ស្ថានទូតអាមេរិក ដោយបង្ហាញពីការបានបង់ថ្លៃពេញ សំណៅឯកសារនៃការបង់ពន្ធរថយន្ត និងសំណៅនៃឯកសារលើកលែងពន្ធរថយន្ត (ចំពោះស្ថាប័នដែលសុំការលើកលែងពន្ធ)។
- សម្រាប់ពត៌មានបន្ថែម ឬចម្ងល់ផ្សេងៗ សូមទំនាក់ទំនងលោកសំ សុភី តាមរយៈទូរស័ព្ទលេខ ០២៣៧២៨៥០៣ ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ រៀងរាល់ម៉ោងធ្វើការ
- បុគ្គលិករបស់ស្ថានទូតអាមេរិកដែលធ្វើការទាក់ទងនឹងផ្នែកភស្តុភាក្នុងការដេញថ្លៃនេះត្រូវបានហាមមិនអោយធ្វើការដេញថ្លៃទេ។

***រូបភាពរថយន្ត:***



08/14
Có hiệu lực đến ngày
05/08/2014
CỤC ĐĂNG KIỂM VIỆT NAM
Ministry of Public Works and Transport
General Direction of Transport
Cambodia Motor Vehicle Inspection
10.09.2016
CD 25-166
TO.LANDCRUISER
4477
1996
800,000
2019




km/h
x1000r/min
ODO 81697










4500 EFI